Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្ដីសម្រេចប្រកបដោយសុវត្ថិភាព ក្នុងអំឡុងពេលព្យុះភ្លៀង



## ស្វែងរក និងស្ដាប់ការព្រមានអំពី អាកាសធាតុ

ស្វែងរក និងស្ដាប់ការព្រមានអំពីការព្រមានទាក់ទងនឹងព្យុះភ្លៀងអាកាសធាតុដែលបានចេញពីការិយាល័យឧតុនិយម រួមមាន **ការព្រមានអំពីអាកាសធាតុធ្ងន់ធ្ងរ** និង **ការព្រមានអំពីព្យុះមានភ្លៀងរន្ទះធ្ងន់ធ្ងរ**។

NSW SES នឹងចេញ **ដំបូន្មាន, ការឃ្លាំមើល និងការធ្វើសកម្មភាព** ឬ **ការព្រមានក្នុងគ្រាអាសន្ន**។ កម្រិតនៃការព្រមានគឺអាស្រ័យលើផលប៉ះពាល់ និងផលវិបាកដែលរំពឹងទុកពីព្យុះភ្លៀង។

ការព្រមានទាំងនេះនឹងបង្ហាញនៅលើកម្មវិធី **គ្រោះថ្នាក់នៅជិតខ្ញុំ (Hazards Near Me** app)។



## ចាត់វិធានការប្រកបដោយសុវត្ថិភាព

1. ធានាឱ្យមានសុវត្ថិភាព ឬដាក់វត្ថុរលុងៗចេញឱ្យឆ្ងាយពីទីធ្លាផ្ទះរបស់អ្នក ឬយ៉ផ្ទះរបស់អ្នក ឧទាហរណ៍៖ ត្រាំប៉ូលីន ឆ័ត្រ តុនិងកៅអី និងចានដាក់ចំណីសត្វចិញ្ចឹម។
2. ចតរថយន្តនៅក្រោមជម្រកមានដំបូលសុវត្ថិភាព (យានដ្ឋាន ចំណតរថយន្ត) ឱ្យឆ្ងាយពីដើមឈើ ខ្សែភ្លើង និងតំបន់ទំនាប។
3. ធានាថាកូនៗ និងសត្វដែលស្ថិតនៅក្នុងការថែទាំរបស់អ្នក ត្រូវបាននាំចូលទៅខាងក្នុងកន្លែងដែលមានសុវត្ថិភាព។




## តាមដាន លក្ខខណ្ឌអាកាសធាតុនៅតាមតំបន់

ត្រូវប្រាកដថាអ្នកជិតខាង ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកដឹងអំពីការព្រមានបច្ចុប្បន្ន។

ស្ដាប់វិទ្យុ និងទូរទស្សន៍នៅតាមតំបន់របស់អ្នក ដើម្បីទទួលបានបច្ចុប្បន្នភាពថ្មីៗអំពីអាកាសធាតុ។

អនុវត្តតាមដំបូន្មានទាំងអស់ពីសេវាសង្គ្រោះបន្ទាន់។

ក្នុងស្ថានភាព
គំរាមកំហែងដល់ជីវិត
**ហៅទូរសព្ទទៅលេខ
សូន្យបីង (000)**

សម្រាប់ជំនួយក្នុងគ្រាអាសន្នដោយសារទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES   NSWSES   NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្តីសម្រេចប្រកបដោយ សុវត្ថិភាព ក្នុងអំឡុងពេលព្យុះភ្លៀង

## បន្តស្នាក់នៅ ផ្ទះមាន សុវត្ថិភាព

- ស្នាក់នៅខាងក្នុងអគារ នៅឆ្ងាយពីទ្វារ និងបង្អួច។
- ពិចារណាឡើងវិញអំពីការបើកបរ ឬការធ្វើដំណើរ ក្នុងអំឡុងពេលមានព្យុះភ្លៀង។



## បន្តមានសុវត្ថិភាពប្រសិនបើ កំពុងបើកបរ



1. បន្ថយល្បឿន និងបើកបរទៅតាមស្ថានភាពនានា។



2. ចូរឈប់តាមដងផ្លូវដើម្បីស្វែងរកទីជម្រកដែលស្ថិតនៅទីតាំងមានសុវត្ថិភាព ជាការប្រសើរគឺនៅឆ្ងាយពីដើមឈើ ខ្សែភ្លើង និងតំបន់ទំនាប។




3. ពិនិត្យមើល **ចរាចរណ៍ផ្សាយផ្ទាល់** និង ស្តាប់ព័ត៌មានថ្មីៗនៅតាមស្ថានីយ៍វិទ្យុក្នុងតំបន់របស់អ្នក។

## បន្តស្នាក់នៅខាងក្រៅ មានសុវត្ថិភាព

- ហៅទូរសព្ទទៅ NSW SES តាមលេខ 132 500 ប្រសិនបើអ្នកត្រូវការជំនួយសង្គ្រោះបន្ទាន់ ឬលេខសូន្យបីដង (000) ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត។
- រកទីជម្រកដែលមានសុវត្ថិភាព ជាការប្រសើរគឺត្រូវស្ថិតនៅក្នុងអគារ។
- នៅឱ្យឆ្ងាយពីលូ និងផ្លូវទឹក។
- នៅឱ្យឆ្ងាយពីដើមឈើ ខ្សែភ្លើង និងវត្ថុដទៃទៀតដែលអាចធ្លាក់ ឬហើរប៉ើងក្នុងខ្យល់។
- ត្រូវដឹងអំពីរន្ទះ និងជៀសវាងសកម្មភាពនានានៅខាងក្រៅផ្ទះ ដែលអាចធ្វើឱ្យអ្នកប្រឈមនឹងហានិភ័យ។

ក្នុងស្ថានភាព គំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខ សូន្យបីង (000)**

សម្រាប់ជំនួយក្នុងគ្រាអាសន្នដោយសារទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

www.ses.nsw.gov.au/languages

@NSWSES NSWSES NSWSES